# ជំពូកទី ៥

# ការពិគ្រោះយោបល់ជាសាធារណៈ

Draft

Draft

# ជំពូកទី ៥
# ការពិគ្រោះយោបល់សាធារណៈ

## ៥.១ សេចក្តីផ្តើម

ការពិគ្រោះយោបល់ ឬស្ទង់មតិជាសាធារណៈនេះជាផ្នែកមួយដ៏សំខាន់នៃការសិក្សាវាយតំលៃទៅលើផលប៉ះពាល់បរិស្ថាន និងសង្គម ព្រោះវាជាការសិក្សាទស្សនៈ និងយោបល់របស់បណ្តាអ្នកពាក់ព័ន្ធទាំងឡាយក្នុងតំបន់សិក្សា ។ ដោយហេតុថាគម្រោងសិក្សាស្រាវជ្រាវរុករករ៉ែលោហៈរបស់ ក្រុមហ៊ុន **ភូយ៉ាង(ខេមបូឌា)** PHU YANG (CAMBODIA) Co., Ltd អាចនឹងធ្វើឱ្យមាននូវហេតុប៉ះពាល់បរិស្ថាន និងសង្គម ទៅដល់សហគមន៍មូលដ្ឋាន និងក្រុមហ៊ុននានាដែលស្ថិតនៅជុំវិញតំបន់សិក្សា។ ក្រុមហ៊ុន ហ្គ្រីន អ៊ិនវ៉ាយ រ៉ន មិន គ្រុប (GREEN ENVIRONMENT GROUP CO., LTD.) ដែលជាក្រុមហ៊ុនសិក្សាទៅលើហេតុប៉ះពាល់បរិស្ថាន និងសង្គម បានធ្វើការសិក្សាស្រាវជ្រាវ និងវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយផ្អែកទៅលើច្បាប់ និងបទបញ្ញត្តិនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា និងការរៀបចំជាការស្ទង់មតិសាធារណៈ ដោយធ្វើការអញ្ជើញអ្នកពាក់ព័ន្ធឱ្យចូលរួមដូចជា អាជ្ញាធរមូលដ្ឋាន សហគមន៍មូលដ្ឋាន និងបណ្តាអ្នកពាក់ព័ន្ធនានាដើម្បីស្វែងយល់ពីទស្សនៈរបស់អ្នកពាក់ព័ន្ធទាំងនោះ ដែលជាកត្តាមួយអាចសំរាលនូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

## ៥.២ គោលបំណង

ចំពោះគោលបំណងនៃការពិគ្រោះយោបល់ ឬការស្ទង់មតិជាសាធារណៈនេះគឺៈ

- កំណត់ទីតាំងនៃគម្រោងស្នើសុំវិនិយោគសិក្សាស្រាវជ្រាវរុករករ៉ែលោហៈ
- ធ្វើការផ្សព្វផ្សាយឲ្យអ្នកពាក់ព័ន្ធបានយល់ដឹងពីសកម្មភាពគំរោង
- ធ្វើការស្ទាបស្ទង់មតិពីបណ្តាអ្នកពាក់ព័ន្ធនានាទៅលើតំបន់សិក្សាស្រាវជ្រាវ
- ស្វែងយល់ពីបញ្ហានានាដែលអាចនឹងបង្កើតឡើងដោយសារគម្រោង
- ធ្វើការដោះស្រាយរាល់បញ្ហាពាក់ព័ន្ធដែលអាចកើតមានឡើងទៅលើសហគមន៍មូលដ្ឋាន និងទទួលយកសំណូមពរ ឬអនុសាសន៍ពីអ្នកពាក់ព័ន្ធ និងប្រជាជនមូលដ្ឋាន។

## ៥.៣ វិធីសាស្រ្ត និងតំបន់គោលដៅ

ដើម្បីឱ្យរបាយការណ៍វាយតំហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងមានភាពត្រឹមត្រូវ និងច្បាស់លាស់ ក្រុមការងារក្រុមហ៊ុន ហ្គ្រីនអ៊ិនវ៉ាយរ៉នមិន គ្រុប បានប្រើប្រាស់នៅវិធីសាស្រ្តក្នុងការពិភាក្សាជាក្រុម និងការសម្ភាសន៍ក្នុងគោលបំណងដើម្បីស្រង់ព័ត៌មាន និងសុំយោបល់ពីអ្នកពាក់ព័ន្ធនានា ។ ការសម្ភាសន៍ត្រូវបានធ្វើដោយផ្តោតទៅលើៈ

+ មន្ទីរ និងស្ថាប័នជំនាញពាក់ព័ន្ធ
    - មន្ទីរកសិកម្ម ខេត្តបាត់ដំបង
    - មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តបាត់ដំបង
    - មន្ទីរបរិស្ថាន ខេត្តបាត់ដំបង

- មន្ទីរធនធានទឹក និងឧតុនិយមខេត្តបាត់ដំបង
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តបាត់ដំបង
- ខណ្ឌរដ្ឋបាលព្រៃឈើបាត់ដំបង
- ខណ្ឌរដ្ឋបាលជលផលបាត់ដំបង

+ អាជ្ញាធរដែនដី

- អាជ្ញាធរខេត្តបាត់ដំបង
- អាជ្ញាធរស្រុកភ្នំព្រឹក
- អាជ្ញាធរឃុំភ្នំព្រឹក ( ភូមិភ្នំព្រឹក) ។

## ៥.៤ លទ្ធផលនៃការពិភាក្សា

### ៥.៤.១ មន្ទីរ និងស្ថាប័នជំនាញពាក់ព័ន្ធ

ក. មន្ទីរកសិកម្ម ខេត្តបាត់ដំបង

ការពិភាក្សាជាមួយលោក ឈឹម វជិរ អនុប្រធានមន្ទីរកសិកម្មខេត្តបាត់ដំបងត្រូវបានធ្វើឡើងកាលពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ ម៉ោង ១០:០០ នាទីព្រឹក នៅមន្ទីរកសិកម្មខេត្តបាត់ដំបង។

លោកធ្លាប់បានដឹងពីវត្តមានរបស់គម្រោងស្នើសុំសិក្សារុករករ៉ែលោហៈរបស់ក្រុមហ៊ុន Phu Yang នេះដែរ។ លោកមានការគាំទ្រចំពោះគំរោងនេះ ព្រោះវាអាចមានផលប្រយោជន៍ដូចជា:

- បង់ពន្ធចូលរដ្ឋ
- ជៀសវាងការធ្វើចំណាកស្រុក
- ជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ
- ទាញកំលាំងពលកម្មមកចូលបំរើក្នុងក្រុមហ៊ុន
- សង្ឃឹមថាបរិស្ថានក្នុងតំបន់នឹងមានការកែលំអរឡើងវិញ

ផលប៉ះពាល់

- លំនៅដ្ឋាន
- ដីស្រែ ចំការរបស់ប្រជាជន
- ការហូរច្រោះដី

សំណូមពរ

- សូមឲ្យគោរពតាមផែនការមេ
- សូមឲ្យក្រុមហ៊ុនដាំដើមឈើឡើងវិញ
- សូមអោយក្រុមហ៊ុនធ្វើការចរចារ និងសំរបសំរួលជាមួយអាជ្ញាធរពាក់ព័ន្ធ និងប្រជាជនដែលប៉ះពាល់

  ជំហ៊ានទី១: មុននឹងចុះសិក្សា សូមឲ្យក្រុមហ៊ុនជួបជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន (ប្រសិនបើប៉ះពាល់) ។

  ជំហ៊ានទី២: អាចបង្កើតអនុគណៈកម្មការថ្នាក់ស្រុក ខេត្តចូលរួម ដើម្បីសិក្សាបន្ត។



Draft

- បើសិនជាមានដីស្រែ ចំការរបស់ប្រជាជនប៉ះពាល់ សូមឲ្យក្រុមហ៊ុនមកធ្វើការដោះស្រាយជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាជនឲ្យបានសមស្រប ៕

ខ. មន្ទីរបរិស្ថានខេត្តបាត់ដំបង

ក្រុមសិក្សាបានជួបពិភាក្សាជាមួយលោក ឆាយ យូប ប្រធានមន្ទីរបរិស្ថាន ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ម៉ោង ០៣:០០ នាទីព្រឹក នៅមន្ទីរបរិស្ថាន ខេត្តបាត់ដំបង។

លោកមានប្រសាសន៍ថាលោកធ្លាប់បានដឹងពីវត្តមានរបស់គម្រោងសិក្សារុករករ៉ែលោហៈនេះតាំងពីឆ្នាំ ២០០៧ ប៉ុន្តែក្រុមហ៊ុននេះទទួលបានអាជ្ញាប័ណ្ណមួយតាំងពីឆ្នាំ ២០០៦។

លោកបានឲ្យដឹងទៀតថាប្រជាជនដែលរស់នៅក្នុងតំបន់គំរោងស្នើសុំមានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន។ លោកមានការពេញចិត្តក្នុងការអភិវឌ្ឍន៍ និងគម្រោងសិក្សាស្រាវជ្រាវរុករករ៉ែនេះ។ ក្នុងតំបន់គម្រោងស្នើសុំអាចមានសត្វព្រៃមួយចំនួនដូចជា ពស់ ជ្រូកព្រៃ។ ក្នុងតំបន់នេះផងដែរមានអូរមួយឈ្មោះថាអូរព្រំដែន ដែលមានទឹកពេញមួយឆ្នាំ។

លោកបានបន្ថែមថា ក្នុងតំបន់គម្រោងមានទឹកធ្លាក់មួយកន្លែង ឯព្រៃមានតិច (លក្ខណៈព្រៃភ្នំ) ។ នៅតាមជើងភ្នំមិនមានព្រៃទេ ហើយក៏គ្មានប្រភេទឈើដែលមានតំលៃសេដ្ឋកិច្ចដែរ។

ផលប៉ះពាល់

- ភ្នំ និងដីស្រែ ចំការ (ចំការមានច្រើនជាងស្រែ)
- ដីលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ
- ទឹកប្រើប្រាស់ ។

សំណូមពរ

- សូមឲ្យក្រុមហ៊ុនសិក្សាឡើងវិញ ធ្វើយ៉ាងណាកុំឲ្យជាន់គ្នាលើក្រុមហ៊ុនវិនិយោគផ្សេងទៀត
- ធ្វើការសិក្សាឲ្យបានម៉ត់ចត់ និងលំអិត ដើម្បីកុំឲ្យប៉ះពាល់ដល់ប្រជាជន និងប្រទេសជិតខាង
- សូមឲ្យក្រុមហ៊ុនធ្វើការសំរបសំរួលជាមួយប្រជាជន
- សូមទុកដីឯកជនរបស់របស់រដ្ឋដូចជា សាលារៀន ប៉ុស្តិ៍នគរបាល មន្ទីរពេទ្យ។ល។
- ក្រោយពេលរុករករ៉ែលោហៈហើយ ក្រុមហ៊ុនត្រូវរៀបចំកែច្នៃ៕

គ. មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តបាត់ដំបង

ក្រុមសិក្សាបានជួបពិភាក្សាជាមួយលោក ងួន រតនៈ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តបាត់ដំបង កាលពីថ្ងៃទី ២០ខែ កក្កដា ឆ្នាំ ២០១១ នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តបាត់ដំបង។

លោកមានប្រសាសន៍ថាលោកមិនធ្លាប់បានដឹងពីវត្តមានរបស់គម្រោងសិក្សារុករករ៉ែលោហៈ នៅតំបន់ភ្នំព្រឹក ស្រុកភ្នំព្រឹកទេ។ ចំពោះគម្រោងដែលស្នើសុំខាងលើ មន្ទីរមានការងារឯកភាពក្នុងករណីផ្តល់អត្ថប្រយោជន៍ និងដល់ប្រជាជនច្រើន និងមានការគិតគូរពីសំណងត្រឹមត្រូវ។

ផលប៉ះពាល់

- បាត់បង់លំនៅដ្ឋាន និងដីកសិកម្មនាំឲ្យមានចំណាកស្រុក

- ប៉ះពាល់សុខភាព
- ប៉ះពាល់ដល់ប្រទេសជិតខាង(ជំលោះ) និងតំបន់នៅជុំវិញ
- បាត់បង់ព្រៃឈើ និងជំរកសត្វព្រៃ
- ផុតពូជ រុក្ខជាតិ សត្វ
- តើប្រែប្រួលអ្វីខ្លះលើគម្របព្រៃឈើ?
- ទឹកកខ្វក់ , បំពុលបរិយាកាស(អាកាសធាតុប្រែប្រួល),ទីជំរាល(បាក់ដី)
- ដីខូចគុណភាព និងអាចកែខៃបាន,ទឹកក្រោមដីហូរខុសប្រក្រតី
- បាត់បងជីវៈចំរុះ ,តើរបៀបគ្រប់គ្រងកាកសំណល់យ៉ាងដូចម្តេច?

ផលប្រយោជន៍

- មានការងារធ្វើ(រោងចក្រ និងជីវភាពធូធារ)
- ហេដ្ឋារចនាសម្ព័ន្ធថ្មីៗ(ផ្លូវ ផ្សារ មន្ទីរពេទ្យ សាលារៀន)
- ចំណូលសេដ្ឋកិច្ចក្នុងស្រុក
- ប្រជាពលរដ្ឋនៅទីនោះមានការងារធ្វើ
- នៅឆ្ងាយពីតំបន់ការពារធម្មជាតិ

លោកមន្ទីរបានចេញសិទ្ធិមួយចំនួន ម្យ៉ាងវិញទៀតប្រជាជននៅតំបន់នោះ ភាគច្រើនពួកគាត់មករស់នៅតាំងពីយូរណាស់មកហើយ ដែលជាដីកម្មសិទ្ធិរបស់គាត់។ ប្រសិនបើក្រុមហ៊ុនវិនិយោគស្នើសុំ ប៉ះពាល់លើដីប្រជាជន លោកមានវិធានការដើម្បីដោះស្រាយ គឺផ្តោតសំខាន់ទៅលើសំណងសមស្របឲ្យប្រជាជនដែលរស់នៅទីនោះ និងផ្តល់ការងារឲ្យពួកគាត់។

សំណូមពរ

- ក្រុមហ៊ុនគួរតែចុះសិក្សាស្រាវជ្រាវផ្ទាល់ និងវាយតំលៃប៉ះពាល់បរិស្ថានឲ្យបានស៊ីជំរៅ និងច្បាស់លាស់។
- គួរតែសិក្សា និងធ្វើផែនការអភិវឌ្ឍន៍ឲ្យបានច្បាស់លាស់នៅតំបន់រុករករ៉ែ និងតំបន់ជុំវិញ។
- គួរតែ ស្រង់ទិន្នន័យឲ្យបានច្បាស់លាស់(ទំហំ ទីតាំង ចំនួនប្រជាជន) ដែលរងនូវការ ប៉ះពាល់ដោយសារគេម្រោងនេះ។
- បន្ទាប់ពីគម្រោងត្រូវបានបញ្ចប់ក្រុមហ៊ុនគួរតែត្រូវដាំដើមឈើឡើងវិញ។
- គួរសិក្សាគម្រោងសាកល្បងទៅលើទំហំផ្ទៃដីតូចជាមុនសិន។
- ប្រើប្រាស់កំលាំងពលកម្ម ពីប្រជាជនដែលរស់នៅទីនោះផ្ទាល់៕

### ឃ. មន្ទីរធនធានទឹក និងឧតុនិយមខេត្តបាត់ដំបង

ក្រុមសិក្សាបានជួបពិភាក្សាជាមួយលោក ខែ សុជា អនុប្រធានមន្ទីរធនធានទឹក និងឧតុនិយម ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១ ម៉ោង ០៩:២០ នាទីព្រឹក នៅមន្ទីរធនធានទឹក និងឧតុនិយមខេត្តបាត់ដំបង។

លោកមានប្រសាសន៍ថាលោកពុំធ្លាប់បានដឹងពីវត្តមានរបស់គម្រោងវិនិយោគនេះទេ។ លោកមានការគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍នេះ ទាមទារឲ្យសិក្សាពីផលប៉ះពាល់ឲ្យបានច្បាស់ និងការឯកភាពពីមន្ទីរពាក់ព័ន្ធជាមុនសិន។

ផលប្រយោជន៍

- កាត់បន្ថយភាពក្រីក្រ
- ប្រជាជនមានការងារធ្វើជាកម្មកររបស់ក្រុមហ៊ុន

ផលប៉ះពាល់

- ប៉ះពាល់លើដីស្រែចំការរបស់ប្រជាជន
- ប៉ះពាល់ដល់ការបំពុលប្រភពទឹក

បើសិនសិក្សាទៅឃើញមានការប៉ះពាល់តិចតួចនោះក្រុមហ៊ុនអាចដំណើរការវិនិយោគបាន។ ចំពោះប្រភពទឹកនៅក្នុងតំបន់មានប្រភពទឹកសំខាន់អ្វីខ្លះ? ប្រភពទឹករាងរងការបំពុលដោយសារធាតុរំលាយរ៉ែ និងប្រើសារធាតុគីមីរនៅក្នុងប្រភពទឹកទាំងនោះ។ អូរព្រំដែនមានទឹកទាំងវស្សា និងប្រាំង និងអូរល្អុងមានតែវស្សា។ នៅក្នុងតំបន់នេះមិនសូវមានប្រភពទឹកសំខាន់ៗប៉ុន្មានទេ។

សំណូមពរ

- សូមឲ្យក្រុមហ៊ុនទាញយកកំលាំងពលកម្មក្នុងស្រុកឲ្យបានប្រើប្រាស់ ដើម្បីកាត់បន្ថយចំណាកស្រុក និងកាត់បន្ថយភាពក្រីក្រ៕

ង. មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តបាត់ដំបង

ក្រុមសិក្សាបានជួបពិភាក្សាជាមួយលោក ជី ឈៀង ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ម៉ោង ០៩:៥០ នាទីព្រឹក នៅមន្ទីរឧស្សាហកម្មរ៉ែ និងថាមពលខេត្តបាត់ដំបង។

លោកមានប្រសាសន៍ថាលោកធ្លាប់បានដឹងពីវត្តមានរបស់គម្រោងជាលើកទីបីហើយ ។ លោកមានការឯកភាពទៅលើគម្រោងប៉ុន្តែត្រូវមានការទំនាក់ទំនងជាមួយក្រសួងនិងមន្ទីរពាក់ព័ន្ធ ។ ក្រុមហ៊ុនមិនមានទំនាក់ទំនងជាមួយលោកប្រធានមន្ទីរទេ នៅពេលក្រុមហ៊ុនមានបញ្ហាទើបមកជួបលោកប្រធាន។

ផលប្រយោជន៍

- ប្រជាជនមានការងារធ្វើ
- បង់ពន្ធចូលរដ្ឋ

ផលប៉ះពាល់

- ពាក់ព័ន្ធនិងបរិស្ថាន
- បំពុលដល់បរិស្ថាន

សំណូមពរ

- សូមឲ្យក្រុមហ៊ុនទទួលតាមស្ថាប័នពាក់ព័ន្ធនៅពេលស្រុក ឃុំ និងភូមិត្រូវរាយការណ៍ដល់អាជ្ញាធរ
- សូមឲ្យក្រុមហ៊ុនទំនាក់ទំនងល្អជាមួយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ៕

ច. ខណ្ឌរដ្ឋបាលព្រៃឈើបាត់ដំបង

ការពិភាក្សាជាមួយលោក គួច មុនី នាយរងខណ្ឌរដ្ឋបាលព្រៃឈើបាត់ដំបងត្រូវបានធ្វើឡើងកាលពីថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ ២០១១ ម៉ោង ០៨:៤០ នាទីព្រឹក នៅខណ្ឌរដ្ឋបាលព្រៃឈើបាត់ដំបង។

លោកបានមានប្រសាសន៍ថា លោកមិនធ្លាប់បានដឹងពីវត្តមានរបស់គម្រោងស្នើសុំវិនិយោគនេះពីមុនមកទេ ហើយក៏មិនមានឯកសារណាមកបង្ហាញដែរអំពីគម្រោងវិនិយោគនេះ ។ លោកមានការគាំទ្រប៉ុន្តែសូមឲ្យក្រុមការងារចុះសិក្សាឲ្យបានលំអិតជៀងវាងការជាន់គ្នានៅក្នុងតំបន់សក្តានុពលសហគមន៍ព្រៃឈើក្នុងគម្រោងការ ។

-ស្ថានភាពព្រៃសព្វថ្ងៃនៅខ្លះដូចជា នៅអូររំដួល គឺព្រៃនៅតាមតំបន់ភ្នំ

-នៅតំបន់ភ្នំព្រឹកមានសហគមន៍ព្រៃឈើរួចមកហើយនៅក្នុងឃុំភ្នំព្រឹកដែលចេញប្រកាសដោយក្រសួងកសិកម្ម។នៅក្នុងអូររំដួលមានសហគមន៍មួយកំពុងត្រៀមរៀបចំដំណើរការសក្តានុពលព្រៃសហគមន៍ព្រៃឈើអូររំដួល។

-តំបន់ដែលមានសក្តានុពលព្រៃសហគមន៍នៅភ្នំព្រឹកឃុំអូររំដួលដែលមានផ្ទៃដី៤៦៣៥ហិកតា និងស្រុកភ្នំព្រឹក ឃុំភ្នំព្រឹក ផ្ទៃដី៤៥៤៩ហិកតា។

-សព្វថ្ងៃមានសត្វមួយចំនួននិងព្រៃឈើមាននៅតាមលើភ្នំ ចំណែកកុំងជើងភ្នំវិញសុទ្ធតែចំការ។

ផលប្រយោជន៍

- ផ្តល់ថវិកាជូនជាតិ
- ប្រជាជនមានការងារធ្វើ

ផលប៉ះពាល់

- ប៉ះពាល់ដល់វិស័យកសិកម្ម
- ការបាត់បង់សត្វព្រៃ
- ប៉ះពាល់ដល់ដីកសិកម្ម( ជីវជាតិដីធ្លាក់ចុះ)
- ការបំពុលជាសំលេងដល់សត្វព្រៃ
- ការយករ៉ែវាប៉ះពាល់ការប្រើប្រាស់ទឹករបស់ប្រជាជន

សំណូមពរ

- សូមឲ្យការពារព្រៃទ្រនាប់ដងអូរ
- ក្នុងករណីប៉ះពាល់ដល់ដីចំការរបស់ប្រជាជនសូមឲ្យក្រុមហ៊ុនមានដំណោះស្រាយសមស្របដើម្បីរកកំរិតឯកភាពគ្នា
- ប្រសិនបើក្រុមហ៊ុនវិនិយោគជាន់គ្នាលើតំបន់សក្តានុពលសហគមន៍ព្រៃឈើជាដំណោះស្រាយសូមឲ្យខាងរដ្ឋាភិបាលជាអ្នកសំរេចជាផលប្រយោជន៍ជាតិនិងប្រជាជន ៕

ឆ. ខណ្ឌរដ្ឋបាលជលផលបាត់ដំបង

ការពិភាក្សាជាមួយលោក ជួង សុភា នាយរងខណ្ឌរដ្ឋបាលជលផលបាត់ដំបងត្រូវបានធ្វើឡើងកាលពីថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ ម៉ោង ៣:៣០ នាទីរសៀល នៅខណ្ឌរដ្ឋបាលជលផលបាត់ដំបង។

លោកបានមានប្រសាសន៍ថា លោកមិនធ្លាប់បានដឹងពីវត្តមានរបស់គម្រោងស្នើសុំវិនិយោគសិក្សាស្រាវជ្រាវរុករករ៉ែលោហៈនេះទេ។

លោកមិនមានការជំទាស់ចំពោះវត្តមានគំរោងស្នើសុំនេះទេ ប៉ុន្តែសូមឲ្យមានការសិក្សាពីផលប៉ះពាល់ឲ្យបានលំអិត ។

-ក្នុងតំបន់ដែលគំរោងស្នើសុំនេះមានអូរប៉ុន្តែចំពោះប្រភេទត្រីទាមទារឲ្យមានការសិក្សាឲ្យបានច្បាស់
-ចំពោះអូរដែលសំបូរថ្ម គឺសំបូរប្រភេទត្រីឆ្លាំង

ផលប្រយោជន៍

- អាចស្រូបយកកំលាំងពលកម្មក្នុងមូលដ្ឋានឲ្យបំរើការងារ

ផលប៉ះពាល់

- អាចប៉ះពាល់ដល់ដីលំនៅដ្ឋាន និងស្រែចំការរបស់ប្រពលរដ្ឋ

សំណូមពរ

- សូមឲ្យក្រុមហ៊ុនវិនិយោគធ្វើការសហការជាមួយអាជ្ញាធរនិងស្ថាប័នជំនាញពាក់ព័ន្ធចុះទៅពិនិត្យទីតាំងផ្ទាល់
- សូមឲ្យក្រុមហ៊ុនធ្វើការដោះស្រាយជាមួយប្រជាជនដែលប៉ះពាល់ឲ្យបានសមស្រប ៕

## ៥.៤.២ អាជ្ញាធរដែនដី

ក. អាជ្ញាធរខេត្តបាត់ដំបង

ការជួបប្រជុំពិភាក្សាជាមួយឯកឧត្តម ស៊ិន ហេង អភិបាលរងខេត្តបាត់ដំបង ត្រូវបានធ្វើឡើងកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១១ ម៉ោង ០៨: ៣០ នាទីព្រឹក នៅសាលាខេត្តបាត់ដំបង។

ឯកឧត្តមបានមានប្រសាសន៍ថា កិច្ចប្រជុំពិភាក្សានេះធ្វើឡើង ដើម្បីពិនិត្យវាយតំលៃលើផលប៉ះពាល់បរិស្ថាន ដែលពាក់ព័ន្ធនឹងការស្រាវជ្រាវធ្វើអាជីវកម្មរុករករ៉ែលោហៈ ហើយមុននឹងមានការប្រជុំថ្ងៃនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាថ្នាក់ជាតិ ក៏បានរៀបចំកិច្ចប្រជុំចំនួនបីលើករួចមកហើយដែរ។ នៅក្នុងគំរោង ក្រុមហ៊ុនបានស្នើសុំអាជ្ញាប័ណ្ណចុះធ្វើការសិក្សាស្រាវជ្រាវរុករករ៉ែលោហៈ នៅតំបន់ភ្នំព្រឹក លើផ្ទៃដីទំហំ ៦៨គីឡូម៉ែត្រក្រឡា ប៉ុន្តែក្រោយមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានអនុញ្ញាតផ្តល់អាជ្ញាប័ណ្ណឲ្យក្រុមហ៊ុនធ្វើអាជីវកម្មតែក្នុងរង្វង់ ០៨គីឡូម៉ែត្រក្រឡាប៉ុណ្ណោះ។

សំណូមពរ

- ក្រុមហ៊ុនត្រូវអនុវត្តតាមគំរោងគឺ អភិរក្ស និងអភិវឌ្ឍន៍។
- ក្រុមហ៊ុនត្រូវធានាឲ្យបាននូវផលប៉ះពាល់បរិស្ថាន។
- នៅពេលខាងមុខ ខាងខេត្តនឹងរៀបចំក្រុមការងារ ដើម្បីចុះវាយតំលៃពីផលប៉ះពាល់ និងចាត់វិធានការចំពោះក្រុមរុករករ៉ែអនាធិតេយ្យ។
- ក្រុមការងារត្រូវធ្វើការដោះស្រាយផលប៉ះពាល់ដីធ្លីជាមួយប្រជាពលរដ្ឋ ដោយសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន។

Draft

ខ. អាជ្ញាធរស្រុកភ្នំព្រឹក

ការពិភាក្សាជាមួយលោក សួន គៀន អភិបាលស្រុកភ្នំព្រឹក ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ម៉ោង ៣:២០ នាទីរសៀល នៅសាលាស្រុកភ្នំព្រឹក ។

លោកអភិបាលស្រុកបានមានប្រសាសន៍ថា លោកបានដឹងពីវត្តមានរបស់គំរោងស្នើសុំវិនិយោគ Phu Yang កាលពីមុនមកនេះ។

លោកមានការគាំទ្រ និងគម្រោងវិនិយោគនេះដោយស្របតាមគោលនយោបាយរបស់រដ្ឋាភិបាល ។

- នៅក្នុងដីគម្រោងមានផ្ទៃដី ៦៨គីឡូម៉ែត្រក្រឡាសុទ្ធតែប្រជាជនរស់នៅ
- ប្រជាជននៅក្នុងតំបន់គម្រោងមានប្រជាជនទៅរករ៉ែនៅក្នុងតំបន់គម្រោងដោយប្រើប្រាស់ដោយដៃ
- នៅក្នុងតំបន់គម្រោងមានដីស្រែចំការរបស់ប្រជាជនហើយមិនមានព្រៃទេ
- នៅក្នុងតំបន់គម្រោងមានព្រៃសហគបន៍មួយនៅក្នុងឃុំភ្នំព្រឹក(ជាព្រៃលើភ្នំ)
- នៅឃុំអូររំដួលនិងពេជ្រចិន្តាមានសហគមន៍កសិកម្មមួយ

ផលប៉ះពាល់

- ដល់ដីស្រែចាំការរបស់ប្រជាជន និងលំនៅដ្ឋានហើយមិនប៉ះពាល់ដល់ដីព្រៃទេ ព្រោះគ្មានព្រៃនៅក្នុងតំបន់នោះ
- ប៉ះពាល់ដល់មុខរបររបស់ប្រជាជន

ផលប្រយោជន៍

- ចំណូលចូលរដ្ឋតាមរយៈការបង់ពន្ធ
- ក្រុមហ៊ុនអាចកសាងហេដ្ឋារចនាសម្ព័ន្ធ
- ប្រជាជនមានការងារ និងកាត់បន្ថយការធ្វើសំណាកស្រុក

សំណូមពរ

- បើប៉ះពាល់ដល់ដីរបស់ប្រជាជនសូមឲ្យក្រុមហ៊ុនត្រូវដោះស្រាយដូចជាប្រជាជនឲ្យបានសមស្រប
- សូមឲ្យក្រុមហ៊ុនកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ ៕

Draft

គ. អាជ្ញាធរឃុំភ្នំព្រឹក

ការពិភាក្សាជាមួយលោក ម៉ែន សែប មេឃុំភ្នំព្រឹក បានធ្វើឡើង កាលពីថ្ងៃទី ០៤ ខែ មករាឆ្នាំ ២០១២ ម៉ោង ០៩:២០ នាទីព្រឹក នៅសាលាឃុំភ្នំព្រឹក ។

លោកធ្លាប់បានដឹង និងទទួលបានឯកសារអាជ្ញាប័ណ្ណធ្វើអាជីវកម្ម និងរុករករ៉ែលោហៈរបស់ក្រុមហ៊ុន ភូយ៉ាងនេះ ។ លោកមានការពេញចិត្ត និងគាំទ្រចំពោះគំរោងស្នើសុំសិក្សារុករករ៉ែលោហៈនេះព្រោះគំរោងស្នើសុំនេះអាចជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ។

តាមការមើលលើផែនទីផ្ទៃដីធ្វើអាជីវកម្មទំហំ ០៤គីឡូម៉ែត្រក្រឡានេះអាចប៉ះពាល់ដល់ដីរបស់ប្រជាជនភូមិបេងស្អាតប្រហែលជា ០៨គ្រួសារ និងរាចមានការប៉ះពាល់ដល់ដីស្រែចំការ និងដីលំនៅដ្ឋានរបស់ប្រជាជនភូមិភ្នំព្រឹក។ លោកបានឲ្យដឹងទៀតថាក្នុងតំបន់គំរោងនេះមានទីតាំងជីករ៉ែអាណាធិបតេយ្យចំនួន ០៣ កន្លែង ដែលមានរណ្តៅរ៉ែច្រើន។

កន្លងមកខាងឃុំក៏មានវិធានការទប់ស្កាត់ការជីករ៉ែអាណាធិបតេយ្យនេះដែរ តាមរយៈការហៅម្ចាស់អាជីវកម្មជីករ៉ែអាណាធិបតេយ្យមកធ្វើកិច្ចសន្យាជាមួយឃុំ ដើម្បីបញ្ចប់ការជីករ៉ែ ប៉ុន្តែជាក់ស្តែងនៅតែមានការជីកដដែល។ ការជីករ៉ែអាណាធិបតេយ្យបានធ្វើឲ្យមានការបំពុលដល់ប្រភពទឹក(អូរព្រំដែន) និងប៉ះពាល់ដល់បរិស្ថាននៅតំបន់នោះ។ ចំណែកឯរណ្តៅរ៉ែដែលបានជីកគឺមិនបានធ្វើការលុបឲ្យបានត្រឹមត្រូវបន្ទាប់ពីបញ្ឈប់ការជីក។

លោកបានបន្តថា ក្នុងតំបន់គម្រោងស្នើសុំសិក្សារុករករ៉ែលោហៈនេះមិនមាននៅសល់ព្រៃឈើ ដែលមានតំលៃសេដ្ឋកិច្ចទេ ព្រោះភ្នំតូចៗនៅតំបន់នេះបានប្រែក្លាយទៅជាចំការពោត ចំការដំឡូងរបស់ប្រជាពលរដ្ឋអស់ហើយ។ ឯដើមឈើមាននៅសល់តែនៅលើភ្នំព្រឹកបន្តិចបន្តួចប៉ុណ្ណោះ។ ប្រជាជនក្នុងតំបន់នេះមិនអាស្រ័យផលនេសាទ រឺប្រើប្រាស់ទឹកអូរព្រំដែនទេ។

**សំណូមពរ**

- សូមឲ្យក្រុមហ៊ុនធ្វើការចរចាដោះស្រាយជាមួយប្រជាជនដែលប៉ះពាល់អោយបានសមស្របដែលអាចទទួលយកបាន ។

**ឃ. ភូមិភ្នំព្រឹក**

ការពិភាក្សាជាមួយលោក ស៊ុម ម៉ាលី មេភូមិភ្នំព្រឹក បានធ្វើឡើង កាលពីថ្ងៃទី ១០ ខែ មករាឆ្នាំ ២០១២ ម៉ោង ០១:១០ នាទីរសៀល នៅភូមិភ្នំព្រឹក។

លោកមេភូមិធ្លាប់បានដឹងពីវត្តមានរបស់គម្រោងស្នើសុំសិក្សារុករករ៉ែលោហៈនៅតំបន់ភ្នំព្រឹកនេះ។

លោកមេភូមិមានការគាំទ្រនឹងគម្រោងវិនិយោគនេះ ប៉ុន្តែទាមទារអោយក្រុមហ៊ុនដោះស្រាយដីប៉ះពាល់របស់ប្រជាពលរដ្ឋអោយបានសមស្រប។

- ការវិនិយោគរបស់ក្រុមហ៊ុនមានការប៉ះពាល់ដល់ដីលំនៅដ្ឋាន និងដីចំការរបស់ប្រជាជនភូមិភ្នំព្រឹកទំហំប្រហែលជា ២៤២ហិកតា។

**សំណូមពរ**

- សូមឲ្យក្រុមហ៊ុនស្នើសុំវិនិយោគរុករករ៉ែលោហៈនេះចុះទៅចរចារ និងរកដំណោះស្រាយដោយផ្ទាល់ជាមួយប្រជាជនដែលមានដីប៉ះពាល់
- សូមឲ្យក្រុមហ៊ុនធ្វើការដោះស្រាយជាមួយប្រជាជនដែលប៉ះពាល់ឲ្យសមរម្យ និងមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន
- សូមឲ្យក្រុមហ៊ុនជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ(សាលារៀន មណ្ឌលសុខភាព ផ្លូវ វត្តអារាម អណ្តូងទឹក-ល-) ។

**ឃ.១. ប្រជាជនភូមិភ្នំព្រឹក**

ការជួបពិភាក្សាជាមួយប្រជាជនភូមិភ្នំព្រឹក បានធ្វើឡើង កាលពីថ្ងៃទី ០៦ ខែ កក្កដាឆ្នាំ ២០១១ ម៉ោង ០៩:៤០ នាទីព្រឹក នៅសាលាឆទានក្នុងភូមិភ្នំព្រឹក។ (បញ្ជីឈ្មោះប្រជាជនចូលរួមប្រជុំមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី ៥)។

ប្រជាជនភូមិភ្នំព្រឹកធ្លាប់បានដឹងថាមានគេចុះរុករករ៉ែលោហៈ ប៉ុន្តែមិនដឹងថាជាក្រុមហ៊ុនណាទេ ។ប្រជាជនមិនមានការជំទាស់ទៅនឹងគម្រោងស្នើសុំរុករករ៉ែលោហៈនេះទេប្រសិនបើក្រុមហ៊ុនធ្វើតាមការសំណូមពរ និងមានដំណោះស្រាយឲ្យបានសមស្របចំពោះដីដែលប៉ះពាល់។

**សំណូមពរ**

- សូមឲ្យក្រុមហ៊ុនស្នើសុំវិនិយោគរុករករ៉ែលោហៈនេះចុះទៅចរចារ និងរកដំណោះស្រាយដោយផ្ទាល់ជាមួយប្រជាជនដែលមានដីប៉ះពាល់។
- សូមឲ្យក្រុមហ៊ុនធ្វើការដោះស្រាយជាមួយប្រជាជនដែលប៉ះពាល់ឲ្យសមរម្យ និងមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន
- សូមឲ្យក្រុមហ៊ុនជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ(សាលារៀន មណ្ឌលសុខភាព ផ្លូវ វត្តអារាម អណ្តូងទឹក-ល-) ។

Draft

តារាង ៥-១ : ការសង្ខេបពីមតិយោបល់របស់អាជ្ញាធរពាក់ព័ន្ធ

| អ្នកពាក់ព័ន្ធ | មតិយោបល់ | សំណូមពរ |
|---|---|---|
| ក.ស្ថាប័ន និងមន្ទីរជំនាញពាក់ព័ន្ធ | | |
| លោក ឈឹម វេរិក<br>អនុប្រធានមន្ទីរកសិកម្ម<br>ខេត្តបាត់ដំបង | លោកបានដឹងពីវត្តមានរបស់គម្រោងវិនិយោគនេះ លោកមានការគាំទ្រចំពោះគំរោងនេះព្រោះវាអាចមានផលប្រយោជន៍ដូចជាៈ បង់ពន្ធចូលរដ្ឋ,ជៀសវាងការធ្វើចំណាកស្រុក, ជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ,ទាញកំលាំងពលកម្មមកចូលបំរើក្នុងក្រុមហ៊ុន ,សង្ឃឹមថាបរិស្ថានក្នុងតំបន់នឹងមានការកែលំអរឡើងវិញ។<br>ផលប៉ះពាល់ៈលំនៅដ្ឋានដីស្រែចំការរបស់ប្រជាជន,ការហូរច្រោះដី៕ | សូមឲ្យគោរពតាមផែនការមេ ,ក្រុមហ៊ុនដាំដើមឈើឡើងវិញ,ក្រុមហ៊ុនធ្វើការចរចារនិងសំរបសំរួលជាមួយអាជ្ញាធរពាក់ព័ន្ធ និងប្រជាជនដែលប៉ះពាល់។ មុននឹងចុះសិក្សា សូមឲ្យក្រុមហ៊ុនជួបជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន (ប្រសិនបើប៉ះពាល់)។អាចបង្កើតអនុគណៈកម្មការថ្នាក់ស្រុក ខេត្តចូលរូប ដើម្បីសិក្សាបន្ត៕ |
| លោក ឆាយ យូប<br>ប្រធានមន្ទីរបរិស្ថាន<br>ខេត្តបាត់ដំបង | លោកធ្លាប់បានដឹងពីវត្តមានរបស់គម្រោង សិក្សារុករករ៉ែលោហៈនេះ។ លោកដឹងថាប្រជាជនដែលរស់នៅក្នុងតំបន់គំរោងស្នើសុំមានការទទួលស្គាល់ពីអាជ្ញាធរមូល ដ្ឋាន។ លោកមានការពេញចិត្តនិងគម្រោងសិក្សាស្រាវជ្រាវរុករករ៉ែនេះ។ ក្នុងតំបន់គម្រោងស្នើសុំ អាចមានសត្វព្រៃមួយចំនួនដូចជាពស់ ជ្រូកព្រៃ។ នៅតាមជើងភ្នំមិនមានព្រៃទេ ហើយក៏គ្មានប្រភេទឈើដែលមានតំលៃសេដ្ឋកិច្ចដែរ។ផលប៉ះពាល់,ភ្នំ និងដីស្រែ ចំការ ,ដីលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ,ទឹកប្រើប្រាស់៕ | សូមឲ្យក្រុមហ៊ុនសិក្សាឡើងវិញ ធ្វើយ៉ាងណាកុំឲ្យជាន់គ្នាលើក្រុមហ៊ុនវិនិយោគផ្សេងទៀត។ធ្វើការសិក្សាឲ្យបានម៉ត់ចត់កុំឲ្យប៉ះពាល់ដល់ប្រជាជននិងប្រទេសជិតខាង,ធ្វើការសំរបសំរួលជាមួយប្រជាជន,ទុកដីឯកជនរបស់រដ្ឋដូចជា សាលារៀន ប៉ុស្តិ៍នគរបាល មន្ទីរពេទ្យ។ល។៕ |
| លោក ងួន រតនៈ | លោកមិនបានដឹងពីវត្តមានរបស់គម្រោងសិក្សារុក | ក្រុមហ៊ុនគួរតែចុះសិក្សាស្រាវជ្រាវ |

| | | |
|---|---|---|
| ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តបាត់ដំបង | រកែរ៉ែលោហៈទេ។ លោកមន្ទីរមានការងារឯកភាពក្នុងករណីផ្តល់អត្ថប្រយោជន៍ និងដល់ប្រជាជនច្រើន និងមានការគិតគូរពីសំណងត្រឹមត្រូវ។<br>ផលប៉ះពាល់<br>- បាត់បងលំនៅដ្ឋាននិងដីកសិកម្មនាំ<br>- ប៉ះពាល់សុខភាព<br>- បាត់បង់ព្រៃឈើ និងជំរកសត្វព្រៃ<br>- ទឹកកខ្វក់បំពុលបរិយាកាស(អាកាសធាតុប្រែប្រួល),ទីជំរាល(បាក់ដី)<br>- ដីខូចគុណភាពនិងអាចកែខៃបាន,ទឹកក្រោមដីហូរខុសប្រក្រតី<br>- បាត់បងជីវៈចំរុះ,តើរបៀបគ្រប់គ្រងកាកសំណល់យ៉ាងដូចម្តេច?<br>ផលប្រយោជន៍<br>- មានការងារធ្វើ(រោងចក្រ និងជីវភាពធូរធារ)<br>- ហេដ្ឋារចនាសម្ព័ន្ធថ្មីៗ(ផ្លូវ ផ្សារ មន្ទីរពេទ្យ សាលារៀន)<br>- ចំណូលសេដ្ឋកិច្ចក្នុងស្រុក<br>- ប្រជាពលរដ្ឋនៅទីនោះមានការងារធ្វើ<br>- នៅឆ្ងាយពីតំបន់ការពារធម្មជាតិ៕ | ផ្ទាល់ និងវាយតម្លៃប៉ះពាល់បរិស្ថានឲ្យបានស៊ីជំរៅ និងច្បាស់លាស់។<br>- គួរតែសិក្សានិងធ្វើផែនការអភិវឌ្ឍន៍ឲ្យបានច្បាស់លាស់នៅតំបន់រុករករ៉ែ និងតំបន់ជុំវិញ។<br>- គួរតែស្រង់ទិន្នន័យឲ្យបានច្បាស់លាស់(ទំហំ ទីតាំង ចំនួនប្រជាជន) ដែលរងនូវការ ប៉ះពាល់ដោយសារគម្រោងនេះ។<br>- បន្ទាប់ពីគម្រោងត្រូវបានបញ្ចប់ក្រុមហ៊ុនគួរតែត្រូវដាំដើមឈើឡើងវិញ។<br>- គួរសិក្សាគម្រោងសាកល្បងទៅលើទំហំផ្ទៃដីតូចជាមុនសិន។<br>- ប្រើប្រាស់កំលាំងពលកម្មពីប្រជាជនដែលរស់នៅទីនោះផ្ទាល់៕ |
| លោក ខៃ សុជា<br>អនុប្រធានមន្ទីរធនធានទឹក និងឧតុនិយម ខេត្តបាត់ដំបង | លោកពុំ ដឹងពីវត្តមានរបស់គម្រោងវិនិយោគនេះទេ។ លោកមានការគាំទ្រចំពោះគម្រោងនេះ ទាមទារឲ្យសិក្សាពីផលប៉ះពាល់ឲ្យបានច្បាស់ និងការឯកភាពពីមន្ទីរពាក់ព័ន្ធជាមុនសិន។<br>ផលប្រយោជន៍<br>- កាត់បន្ថយភាពក្រីក្រ<br>- ប្រជាជនមានការងារធ្វើជាកម្មកររបស់ក្រុមហ៊ុន។<br>ផលប៉ះពាល់<br>- ប៉ះពាល់លើដីស្រែចំការរបស់ប្រជាជន<br>- ប៉ះពាល់ដល់ការបំពុលប្រភពទឹក<br>បើសិនសិក្សាទៅឃើញមានការប៉ះពាល់តិចតួច នោះក្រុមហ៊ុនអាចដំណើរការវិនិយោគបាន។ | - សូមឲ្យក្រុមហ៊ុនទាញយកកំលាំងពលកម្មក្នុងស្រុកឲ្យបានប្រើប្រាស់ ដើម្បីកាត់បន្ថយចំណាកស្រុក និងកាត់បន្ថយភាពក្រីក្រ៕ |
| លោក ជី ឈៀង<br>ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តបាត់ដំបង | លោកធ្លាប់បានដឹងពីវត្តមានរបស់គម្រោងជាលើកទីបីហើយ ។ លោកឯកភាពទៅលើគម្រោងប៉ុន្តែត្រូវមានការទំនាក់ទំនងជាមួយក្រសួង និងមន្ទីរ | សូមឲ្យក្រុមហ៊ុនទទួលតាមស្ថាប័នពាក់ព័ន្ធនៅពេលស្រុក ឃុំ និងភូមិត្រូវរាយការដល់អាជ្ញាធរ ។ សូមឲ្យក្រុមហ៊ុនទំ |

Draft

| | | |
|---|---|---|
| | ដែល។ការជីករ៉ែអាណាធិបតេយ្យបានធ្វើឲ្យមានការបំពុលដល់ប្រភពទឹក(អូរព្រំដែន) និងប៉ះពាល់ដល់បរិស្ថាននៅតំបន់នោះ។ | |
| លោក ស៊ឹម ម៉ាលី មេភូមិភ្នំព្រីក | លោកមេភូមិធ្លាប់បានដឹងពីវត្តមានរបស់គម្រោងស្នើសុំសិក្សារុករករ៉ែលោហៈ នៅតំបន់ភ្នំព្រីកនេះ ។ការវិនិយោគរបស់ក្រុមហ៊ុនមានការប៉ះពាល់ដល់ដីលំនៅដ្ឋាន និងដីចំការរបស់ប្រជាជនភូមិភ្នំព្រីកទំហំ ប្រហែលជា ២៤២ហិកតា។ | - សូមឲ្យក្រុមហ៊ុនរុករករ៉ែលោហៈនេះចុះទៅចរចានិងរកដំណោះស្រាយដោយផ្ទាល់ជាមួយប្រជាជនដែលមានដីប៉ះពាល់និងមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន<br>សូមឲ្យក្រុមហ៊ុនជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ-ល- ។ |
| គ. ប្រជាជនមូលដ្ឋាន | | |
| ប្រជាជនភូមិភ្នំព្រីក | ប្រជាជនធ្លាប់បានដឹងមានគេចុះរុករករ៉ែលោហៈ ប៉ុន្តែមិនដឹងថាជាក្រុមហ៊ុនណាទេ។ប្រជាជនមិនមានការជំទាស់ទៅនិងគម្រោងស្នើសុំរុករករ៉ែលោហៈនេះទេប្រសិនបើក្រុមហ៊ុនធ្វើតាមការសំណូមពរនិងមានដំណោះស្រាយឲ្យបានសមស្របចំពោះដីដែលប៉ះពាល់ ។ | - សូមឲ្យក្រុមហ៊ុនរុករករ៉ែលោហៈនេះចុះទៅចរចានិងរកដំណោះស្រាយដោយផ្ទាល់ជាមួយប្រជាជនដែលមានដីប៉ះពាល់និងមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន<br>- សូមឲ្យក្រុមហ៊ុនជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ-ល- ។ |

Draft

បញ្ជាក់ យោងតាមការពិគ្រោះយោបល់ខាងលើ អ្នកពាក់ព័ន្ធមួយចំនួនបានលើកឡើងពីហេតុប៉ះពាល់ទៅលើការប្រើប្រាស់ដី ជាពិសេសដីរបស់ប្រជាជន ភូមិបេងស្អាតប្រហែលជា ០៤គ្រួសារ (មតិរបស់លោកមេឃុំភ្នំព្រីក)។ តែតាមការចុះសិក្សាផ្ទៀងផ្ទាត់ទីតាំងវិនិយោគជាមួយនឹងលោកមេភូមិបេងស្អាតបានអោយដឹងថា ផ្ទៃដីពាក់ព័ន្ធរបស់ប្រជាជន ភូមិបេងស្អាតប្រហែលជា ០៤គ្រួសារ គឺពុំមានជាប់ពាក់ព័ន្ធនឹងទីតាំងវិនិយោគទេ។

[illegible]

## ៥.៤.៣ ដំណោះស្រាយរបស់ក្រុមហ៊ុនឆ្លើយតបទៅនឹងសំណូមពរ

- ក្រុមហ៊ុននឹងអនុវត្តទៅតាមបច្ចេកទេសសមស្រប ហើយមានការឯកភាពពីបណ្តាស្ថាប័នជំនាញ
- ក្រុមហ៊ុន នឹងសហការណ៍ជិតស្និតជាមួយអាជ្ញាធរពាក់ព័ន្ធ និងប្រជាជនដើម្បីបញ្ចៀសរាល់បញ្ហាដែលអាចកើតមានជាយថាហេតុ
- ក្រុមហ៊ុន នឹងធ្វើការដោះស្រាយ និងសម្របសម្រួលពីបញ្ហាដីធ្លីពាក់ព័ន្ធរបស់ប្រជាជនអោយបានសមរម្យ [illegible]
- ក្រុមហ៊ុន នឹងព្យាយាមជ្រើសរើសប្រជាជនក្នុងតំបន់អោយបំរើការងារក្នុងក្រុមហ៊ុនអោយអស់ពី លទ្ធភាព [illegible]
- ក្នុងករណីកើតមានបញ្ហាដែលបណ្តាមកពីក្រុមហ៊ុន នោះក្រុមហ៊ុននឹងមានវិធានការណ៍សមរម្យដើម្បីធ្វើការដោះស្រាយទៅកាន់ប្រជាជន និងអោយបានឆាប់រហ័សបំផុត ។

[illegible]



- ហេតុតើម្ដេច [illegible]